# ការសំភាសន៍ជាលើកទី២របស់អ្នកមីងឈួន ស្រី ហៅគង់ ចាន់សុផានី

កៈ អ្នកដែលសំភាសន៍ ញ៉ែម សុគន្ធា ខៈ អ្នកដែលត្រូវគេសំភាសន៍ ឈួន ស្រី

## ជីវប្រវត្តសង្ខេមរបស់អ្នកមីងឈួន ស្រី ហៅគង់ ចាន់សុផានី

អ្នកមីងឈួន ស្រី គាត់បានទទួលការសិក្សាត្រឹមតែថ្នាក់ទី២ទេ ព្រោះតែត្រូវមើលថែម្តាយហើយបញ្ហាជីវភាពគ្រួសារអ្នកមីងត្រូវបានបញ្ឈប់ការសិក្សា ។ អ្នកមីងបានរៀបការបន្ទាប់ពេលបែកជំនាន់ប៉ុល ពត ហើយឥឡូវស្វាមីគាត់បានស្លាប់ដោយសារ គ្រោះថ្នាក់ចរាចរណ៍ត្រូវម៉ូតូបុក ហើយគាត់ត្រូវចិញ្ចឹមកូនតែម្នាក់ឯង។ អ្នកមីងធ្វើការស៊ីឈ្នួលគេដើម្បីចិញ្ចឹមគ្រួសារ ។ គាត់កើតទាន់ជំនាន់សង្គ្រាម នៅក្នុងជំនាន់លន់ នល់ គាត់ឃើញមានការទំលាក់គ្រាប់បែកហើយហើយនៅក្នុងប៉ុល ពតគាត់ជាកងកុមារធ្វើការកាច់ផាងខេត្រហើយម្តាយគាត់ជាអ្នកដាំបាយអោយគេហូប ហើយគាត់ក៏បានបាយហូបខ្លះៗ គាត់បានឃើញគេចងសេកមនុស្សយកទៅសម្លាប់។ សព្វថ្ងៃអ្នកមីងរស់នៅជាមួយកូនហើយធ្វើការកាត់ធ្មីអោយគេដើម្បីចិញ្ចឹមជីវិត។

កៈ
ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកមីងដែលអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិអ្នកមីង ជាលើកទី២ នាងខ្ញុំឈ្មោះញ៉ែម សុគន្ធា ជាអ្នកសំភាសន៍អំពីជីវិតអ្នកមីងនៅក្នុងថ្ងៃនេះ ពួកយើងសំភាសន៍នៅក្នុងខែមេសា ឆ្នាំ២០១៨ ការសំភាសន៍មានទីតាំងស្ថិតនៅក្នុងភូមិកោះគរ ឃុំ រកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ប្រទេសកម្ពុជា។ ហើយអ៊ីចឹងនាងខ្ញុំសូមចាប់ផ្តើមសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីង ដែលគាត់អត់ទាន់បានសំភាសន៍ដូចគាត់អត់ទាន់បាននិយាយអំពីជីវិតរបស់គាត់នៅពេលមុន ថែមទៀត អ៊ីចឹងអ្វីដែលគាត់ចង់និយាយ គាត់អាចនិយាយអំពីជីវីតរបស់គាត់បន្ថែមទៀតផងដែរ។អ៊ីចឹងអ្នកមីងសូមប្រាប់ឈ្មោះពេញរបស់អ្នកមីងម្តងទៀត?ឈ្មោះពេញរបស់អ្នកមិងហា៎??ឈ្មោះ!!

ខៈ អាហ្នឹងឈ្មោះដើមញ៉ុមហ្នឹងហើយគង់ ចាន់សុផានី!!

ក៖ ចាំ!!

ខ៖ គេដាក់កន្លែងនេះឈ្មួន ស្រី!!

ក៖ ចាំ អញ្ចឹងឈ្មួន ស្រី !!

ខ៖
ចាំ!!អញ្ចឹងអ្នកមីងពេលមុនអ្នកមីងបានប្រាប់អំពីដូនតានឹងពីជីវិតអ្នកមីងខ្លះៗអំពីបងប្អូនហើយ
តែដូចជាចង់ដឹងអំពីអ្នកមីងនៅពេលកំពុងសិក្សាហាំ!!

ក៖ អ្នកមីងរៀនបានថ្នាក់ទីប៉ុន្មានដែរ?

ខ៖ ថ្នាក់ទី២។

ក៖ ថ្នាក់ទី២ទេអ្នកមីងណោះ?

ខ៖ ចាំ!!មានចេះអីញ៉ុមមានរៀនចេះអីញ៉ុមឈប់រៀន។

ក៖ ចាំ!!

ខ៖ ម្តាយញ៉ុមឈឺញ៉ុមឈប់រៀនទៅ បើញ៉ុមអត់ឈឈប់អត់មានអ្នកណាមើលគាត់
មានតែម្នាក់ឯងឈប់មើលគាត់ ទៅពេទ្យទៅអីមើលគាត់!!

ក៖ មីងទី២នៅក្មេងណាស់អាយុ៧ ៨ឆ្នាំហ្នឹង!!

ខ៖ នៅក្មេងតើ!!ញ៉ុមនៅរៀន!!

ក៖ ហើយបងប្អូនមីងអីអត់មានអ្នកណាគេជួយ!!
អ់តមានអ្នកណាគេជួយមើលទេម៉ែរបស់អ្នកមីង?

ខ៖ គេជួយដែរតែដូចគេទៅមួយភ្លេតមួយភ្លេតយើងនៅក្នុងបន្ទុកជាមួយគាត់!!

ក៖ ចាំ!!

ខ៖ ទៅមើលអញ្ចឹងគេដេក៤ ៥ថ្ងៃអញ្ចឹងទៅគេទៅ!!ព្រោះអីចោលកូន!!

ក៖ ហ្ន៎ គាត់ជួយដែរ។

ខ៖ ហ្នឹងហើយគេជួយព្រោះអីគេចោលកូនគេ ហើយញ៉ុមនៅមើលគាត់ថៃគាត់អញ្ចឹងទៅ!!

ក៖ ចា៎!!

ខ៖ នៅស្ទឹងមានជ័យកំសត់ណាស់ គ្រាគាត់ឡើង គាត់ចង់មកមើលឡានដេកពេទ្យគេ ពេទ្យគេមិនមែនពេទ្យឈ្នួលណាស់!!ទៅអញ្ចឹងទៅចាក់ថ្នាំទៅបូមទៅចាក់ក្បាលពោះគាត់ហា៎ ចាក់ដាក់កន្តោរទៅ បូម!!

ក៖ សុទ្ធតែទឹកម៉ងទៅមីងហេ?

ខ៖ ហ្នឹងហើយ បូមទៅហើយដូចថាឡើងមកហើយវិញអ៊ិចឹងមក!! ដល់ហើយឡើងមកវិញ!!

ក៖ មីងបូមម៉េចទៅមីង?យកសាវាំងមកបូមទៅចាក់ពោះអញ្ចឹងទៅ?

ខ៖ អត់ទេ ចាក់អាសារ៉ូមយើង ចាក់អាត្រយោរសារ៉ូមធំចាក់អាខាងលើហ្ន៎!!

ក៖ ហ្ន៎!!

ខ៖ ហើយដាក់ហើយបង្ហូរត្រយោយើងនៅខាងនេះហើយបញ្ចូលក្នុងកន្តោរទៅ។

ក៖ អញ្ចឹងទឹកម្តងៗច្រើនណាស់មីងណេះ?

ខ៖ ច្រើនដែរតែនេះវាឡើងវិញដដែល។

ក៖ ចំគិតទៅជំងឺសាហាវណាស់មីង តាមពិតគាត់អត់ស្ទូវហូបទឹកប៉ុន្មានទេ តែជំងឺហ្នឹងធ្វើអោយមនុស្សមានទឹកហ្នឹងម៉ងមីងហេ?

ខ៖ ហ្នឹង ចា៎!!

ក៖ ចំអាទឹកហ្នឹងមកពីណាបានធ្វើអោយពោះធំៗម្ល៉េះណោះ?

ខ៖ មិនថាប្រុសមិនថាស្រីកើតដូចតែគ្នា ប្រុសក៏កើតដែរ!!

ក៖ ចា៎!!

ខ៖ ចាំ!!

ក៖ ហ្នឹងនិយាយទៅភាគច្រើនអ្នកដែលផឹកស្រាត្រូវប្រឈមហ្នឹងជំងឺទៀចទឹកម៉ងមីង!!អើយ!!

ខ៖ ហើយញ៉ុមកាលយកគាត់ទៅស្ទឹងមានជ័យ គាត់ចង់មើលឡាន!!គ្រាគាត់មក ! ហើយគេទៅណាស់មីងទៅដេកហ្នឹងតែមួយយប់ពីរយប់ទេគេចេញទៅបាត់ហើយ ញ៉ុមវិញនៅរាប់ខែ ពីរនាក់ម្តាយហើយស្វាត់ជ្រៀប។

ក៖ ពេទ្យអីគេវិញមីងឈ្មោះ?

ខ៖ អត់ទេពេទ្យគេនៅស្ទឹងមានជ័យ។

ក៖ ពេទ្យឈ្នួលអិចឹងទៅណោះ?

ខ៖ ហ្នឹងហើយពេទ្យឈ្នួល ពេទ្យអីគេហៅពេទ្យអីណោះ!!ហើយគាត់នាំទៅហើយគាត់ថាទៅមើលនៅហ្នឹងទៅ ម៉ែហ្អែងជា ដល់តែទៅមើលដេកប៉ុន្មានខែ ៧ខែ!!

ក៖ ហាំ!!

ខ៖ ទៅអត់ជា ទៅយូរណាស់ ទៅយូរអញ្ចឹងគាត់ចង់ថាដូចថាដល់តែនេះទៅម៉ាក់ញ៉ុមថាហ៊ីមិនបាច់ទិញបាយទេគេដាំបាយក្នុងពេទ្យហ្នឹងអោយហើយ!!

ក៖ ចាំ!!

ខ៖ ចេញលុយអោយគេទៅ យើងពេលចេញទៅផ្ទះយើងគិតលុយអោយគេទៅណាស់!!!

ក៖ ហ៊ឹៗ!!អញ្ចឹងអ្នកមីងអញ្ចឹងសំរាប់អញ្ចេក អ្នកមីងអើរឈប់រៀនអាយុ៧ ៨ឆ្នាំរៀនថ្នាក់ទី២ ដោយសារម្តាយឈឺអ្នកមីងឈប់រៀនហោ?

ខ៖ ហ្នឹងហើយ!!

ក៖ តែពេលគាត់ស្លាប់ គាត់ស្លាប់មុនសង្គ្រាមប៉ុល ពតទៀតអញ្ចឹងបើសិនជាអ្នកមីងនៅអាយុប៉ុន្មានឆ្នាំហ្នឹង?

ខ៖  ហ្នឹងអាយុ ទឹមតែ២០ជាងអី!!

ក៖
ហ្ហ៎មិនមែនទេអញ្ជឹងហ្ហ៎!!អញ្ជឹងបើអ្នកមីងពិតជាអញ្ជឹងមែនអ្នកមីងឈប់រៀនមិនមែនមកពីមើលម្ដាយទេហី?

ខ៖  ញ៉ុមឈប់អញ្ចេក ចាំមើលហា ញ៉ុមឈប់រៀនហ្នឹងណាមួយម្ដាយញ៉ុមឈឺ
ហើយណាមួយញ៉ុមដើរធ្វើការអោយគេដើម្បីយកលុយយកមកចិញ្ចឹមម្ដាយ។

ក៖  ហ្ហ៎អញ្ជឹងដោយសារចិញ្ចឹមម្ដាយ អញ្ចឹងពេលឈឺមីងចំណាស់ណេះហើយទេ!!!

ខ៖  ហ្នឹងហើយ ដល់គាត់ឈឺគាត់ថាគាត់ទុក គាត់ឈឺ
គាត់ឈឺល្មមៗកុំអោយគាត់នៅផ្ទះអញ្ជឹងហ្នឹងគាត់ដើររួចហា៎!!

ក៖ ចា៎!!

ខ៖ ហើយញ៉ុមដើរទៅធ្វើការធ្វើអីដើម្បីចិញ្ចឹមម្ដាយហើយចិញ្ចឹមប្អូន!!

ក៖ អញ្ជឹងអ្នកមីងឈប់រៀនដោយសាររកស៊ីចិញ្ចឹមម្ដាយ
អារឿងម៉ែឈឺណេះអារឿងមីង២០ឆ្នាំជាងហើយណេះទេ!!

ខ៖  ហ្នឹងហើយ។

ក៖  បែកពីរសង្គ្រាមហើយអីហើយអស់ហើយអ្នកមីងណោះ?

ខ៖  ហ្នឹងហើយ!!ចា៎!!!

ក៖ មីងពេលរៀនបឋមសិក្សាហ្នឹងមីងរៀននៅណាដែរ?

ខ៖  មីងរៀននៅសាលាបឋមសិក្សាឈ្វូងលៀប។

ក៖  សុទ្ធតែអ្នកឈ្វូងលៀបហ្នឹងទាំងអស់ហ្នឹងមីងណោះ?

ខ៖ ចា៎!!

កៈ
មីងនៅពីក្មេងដូចជាអើរដូចជាអ្នកមីងមានដែលមានក្ដីស្រម៉ៃអីអត់ថាធ្វើអីពេលអ្នកមីងពេលធំឡើងអញ្ចឹងទៅអ្នកមីអណាស់?

ខៈ ធំឡើងចង់ធ្វើមីអូនឯង តែយើងវាអត់លុយ!! ញ៉ុមចេះតែចង់ហើយណាស់!!

កៈ តែបើសិនជាចង់ ចង់អីគេដែរពេលហ្នឹងហាំ??ពេលចង់ធ្វើហ្នឹងហាំ?គិតស្រម៉ៃហ្ន៎?

ខៈ ស្រម៉ៃចង់ធ្វើការអីគេចង់ ចង់ដែរលតែវាអត់នេះ!!

កៈ តែមិនបានធ្វើទៅអ្នកមីងអញ្ចឹងណេះ?

ខៈ ហ្នឹងហើយ!!

កៈ ដូចថាយើងចង់រៀនពេទ្យរៀនអីអញ្ចឹង ចង់ធ្វើការខាងអីមួយអញ្ចឹងវា ដូចថាយើងអត់ !!កៈចាំ!!ខៈ យើងអត់លុយអត់អី!!

កៈ ដោយសារពេលហ្នឹងក៏!!

ខៈ យើងវាអត់ដែរ។

កៈ យ៉ាប់ដែរ!!

ខៈ ញ៉ុមនិយាយទៅញ៉ុមកំសត់ជាងគេហើយ!!ញ៉ុមអត់ដែលនៅផ្ទះទេមីអូន!! ព្រលឹមឡើងញ៉ុមឆ្មៀងហ្នឹងមួយហ្នឹងទៅអូស ទៅជន្ទាត់កំពឹសជន្ទាត់អីហើយ!!

កៈ បានច្រើនទេមីងកំពឹសអីវ៉ាន់?

ខៈ បានច្រើនតើ!! កន្លះៗឆ្នាំប៉ុនៗមេដៃហ្ន៎!!កំពឹសហាំ!!

កៈ អូយ!!

ខៈ ធំៗណាស់។

កៈ អូយនិយាយអីចឹងមកទំនងឆ្ងាញ់ៗណាស់មីងណេះ?

ខ៖ ទៅអូសកំពឹស!!

ក៖ ចាំ!!

ខ៖ ហើយញ៉ុមមិនដែលនៅផ្ទះទេ
ញ៉ុមហ្នឹងញ៉ុមដើរចិញ្ចឹមប្អូនញ៉ុម!!អើយអោយវារៀនអោយប្អូនរៀន!!

ក៖ ចាំ!!

ខ៖ ហើយដល់ពេលមិនរក នៅផ្ទះទាំងអស់គ្នាបានអីគេហូប!!

ក៖ ចាំ!!

ខ៖ ម្លោះហើយញ៉ុមដើរទៅធ្វើការធ្វើអីអោយគេ។

ក៖ មីងទៅជញ្ជាត់ត្រីហ្នឹងនៅបឹងក្រោយនេះហ្នឹងមែន?

ខ៖ នៅបឹងក្រោយហ្នឹង!!

ក៖ សំបូរត្រីខ្លាំងណាស់មីងណោះពេលមុន?

ខ៖ សំបូរតើ កុំតែឥឡូវគេឆក់អីអស់ មុនកំពឹសអីវ៉ាន់មួយកំនរ!

ក៖ ឡើងស្វេស!!

ខ៖ មុនសំបូរកំពឹស ត្រីកំផ្លៀញ ត្រីអីហ្នឹងចាំ!!

(មិត្តភក្តិ)៖ ហើយមានឈ្លើងអត់?

ខ៖ អត់ទេ តែជញ្ជាត់ទៅពស់ឈើចូល។

ក៖ អូយ!!

ខ៖ ពស់ឈើស្ទូកហ្នឹងចូលក្នុងឈ្មៀង!!

ក៖ អូយខ្លាចណាស់មីងញ៉ុម!!រត់បាត់ហើយ ប៉ុន្មានក៏ដោយ!!

ខ៖
ចូលនេះទៅញ៉ុមចិញ្ចឹមម្ដាយហើយគាត់ថាកូនឯងអោយម៉ាក់ខ្លះកូនឯងទុកទិញមាសខ្លះ!!ក៖ ចាំ!!

ខ៖ ហើយយើងឃើញម្ដាយអត់ហើយយើងមិនអោយគាត់។

ក៖ ហ្នឹងហើយ !! មីងពេលហ្នឹងជញ្ជាត់ត្រីមក គ្រាន់តែសំរាប់ធ្វើម្ហូបតើមីងហីអត់មានយកលក់យកអីណាហីមីងហោ?

ខ៖ ធ្វើម្ហូប!!

ក៖ ហ្ហ៎!!

ខ៖ ហ្នឹងយកមកហ្នឹងធ្វើម្ហូបធ្វើអីហ្នឹង អោយប្អូនអោយអីទៅរៀន!!

ក៖ ឆ្ងាញ់ណាស់លឺជញ្ជាត់ត្រី!!

ខ៖ តែនិយាយអីនៅម៉ុំសិត្យនៅអី គេថាមិនដែលឃើញ!! ញ៉ុមថាម៉េចឃើញញ៉ុមបើម៉ោង៥អីញ៉ុមទៅដល់ព្រៃលិចហើយ!!

ក៖ ហ៊ី!!

ខ៖ អត់ដែលឃើញញ៉ុមទេ។

ក៖ ចាំទៅរកនេះរកនោះទៅមីងណោះ?

ខ៖ ចាំ!!ជួនកាលញ៉ូមទៅធ្វើការអញ្ចឹងទៅម៉ោង៦ញ៉ុមមកពីធ្វើការវិញហើយ!!

ក៖ ចាំ!!

ខ៖ មិនដែលអ្នកណាសួរឃើញញ៉ុមទេ!!ថាហ៊ីបើឃើញអញស្ដីហើយ!! ម៉េចឃើញញ៉ុមម៉ោង៥ទៅបាត់ហើយ ម៉ោង៦មកវិញហើយ។

ក៖ ចាំ!!អ្នកមីងនៅរៀនហាំអ្នកមីងមានមិត្តភក្តិណាអ្នកមីងជិតស្និតអត់មីង?

ខ៖ ជិតស្និតជាមួយ មីមួយនៅព្រែកថីហ្ហ៎!!

កៈ  គាត់ឈ្មោះអីគេវិញ?

ខៈ  គាត់ឈ្មោះតុល!!

កៈ  ចាំ!!ឥឡូវនៅរាប់អានគ្នាទល់សព្វថ្ងៃ?

ខៈ នៅរាប់អានតើ!!មេម៉ាយដូចគ្នា!!

កៈ  គាត់ចឹបានមេម៉ាយដែរ តែប្ដីស្លាប់ដែរឬកក៏ម៉េច?

ខៈ  ប្ដីស្លាប់។

កៈ ហ្នឹងសុទ្ធតែអញ្ចឹងមីងណោះ?

ខៈ  ហ្នឹងហើយ!!

កៈ  ហ្នឹងហើយ!អញ្ចឹងចេះតែរាប់អានគ្នាទល់សព្វថ្ងៃហ្នឹងទៅ?

ខៈ  ហ្នឹងហើយរាប់អានគ្នាទៅ ជួបគ្នាហៅគ្នាទៅ!!

កៈ
ចាំអញ្ចឹងឥឡូវជិតស្និតជាងគេអ្នកណាគេវិញមីង?ជិតស្និតដែលគិតថាជាមិត្តភក្តិរបស់មីងម៉ង
ហាំ?

ខៈ  មានតែវាហ្នឹងមួយទេ រៀនជិតស្និត!!

កៈ ចាំ!!

ខៈ  ក្រៅពីហ្នឹងគ្រាន់តែស្គាល់ គេមានយើងអត់គេមិនសូវចង់រាប់យើងហាំ!!

កៈ  ហ្នឹងហើយភាគច្រើនមនុស្ស!! គេរវល់!!

ខៈ  អាហ្នឹងដូចថា ហ្នឹងហើយ អត់ដូចគ្នាចេះតែរាប់អានគ្នាទៅ។

កៈ អ៊ីចឹងអ្នកមីង សំរាប់ចូលដល់ជីវិតអាពាហ៍ពិពាហ៍របស់អ្នកមីងវិញម្ដង
អ្នកមីងរៀបការជាមួយស្វាមីគាត់តឈ្មោះអីគេដែរអ្នកមីង?

ខ៖  ឈ្មោះពុត វៃ!!

ក៖  ពុត វៃ?

ខ៖ ចា៎!!

ក៖ ចា៎ហ្នឹងហើយ អ៊ីចឹងលោកពូបានស្លាប់ហើយអ្នកមីងណោះ?

ខ៖ ចា៎!!

ក៖ ចា៎អញ្ចឹងនៅក្នុងសំបុត្រមរណភាពរបស់លោកពូ គេដាក់ថាលោកពូឈ្មោះពុត វៃកើតនៅថ្ងៃអង្គារ៍ទី២មិនា១៩៦៩ នៅភូមិកណ្ដាលកោះ ឃុំកោះខ្សាច់ជន្លា ស្រុកស្អាង ខេត្តកណ្ដាល ប្រទេសកម្ពុជា ហ្នឹងហើយ
ហើយម្ដាយរបស់លោកពូគាត់ឈ្មោះហាឪពុករបស់លោកពូវៃឈ្មោះហ៊ុន ពុតកើតនៅថ្ងៃ ហា៎គេអត់ដាក់ថ្ងៃខែទេ គេដាក់តែឆ្នាំ១៩៣៥ ហើយម្ដាយរបស់
ម្ដាយក្មេករបស់អ្នកមីងគាត់ឈ្មោះគិត ង៉ន។

ខ៖  ងន!!

ក៖  ងន!! គាត់កើតនៅក្នុងឆ្នាំ១៩៣៧។
អញ្ចឹងគាត់អ្នកខាងកោះខ្សាច់ជន្លាហ្នឹងដែរអ្នកមីងណោះ?

ខ៖  ហ្នឹងហើយ!!

ក៖  មើលអ្នកមីងនិយាយពីប្រវត្តិស្នេហាអ្នកមីងបន្តិចមើល !! ម៉េចបានជួបគ្នា មើលដោយសារពូអ្នកនៅកោះខ្សាច់ជន្លាមីងអ្នកនៅណោះហ្នឹង?

ខ៖ គាត់បានមកនៅផ្ទះបងប្អូនគាត់ជីដូនមួយ !!

ក៖ ចា៎!!

ខ៖  ដល់ហើយគាត់ឃើញគាត់ស្រលាញ់!!

ក៖  ហ៊ឺៗ!!ឃើញស្រលាញ់អ្នកមីងអញ្ចឹងទៅណោះ?

ខ៖  ចាំហ្នឹងហើយ!!

ក៖ ចាំហ្នឹងហើយ !! អញ្ចឹងអ្នកមីងពេលហ្នឹងដឹងថាគេលួចស្រលាញ់អត់អ្នកមីង?

ខ៖  អត់ដឹងទេ ដូចអត់ដឹងទេ!!

ក៖ ចាំ!!អញ្ចឹងអ្នកមីងដូចថាគេចូលស្ដីដណ្ដឹងក៏ព្រមតាមទៅមីងណោះ?

ខ៖  ចាំ!!

ក៖  ពេលហ្នឹងគាត់ចូលស្ដីដណ្ដឹង!តែមីងពេលមុនធ្លាប់ឃើញគាត់អត់អញ្ចឹង?

ខ ញុំមឃើញគាត់មកបងប្អូនគាត់។

ក៖ ចាំតែក៏អត់ទាន់លួចស្រលាញ់អីណាដែរមីងណោះ?

ខ៖  ចាំ
គ្រាន់តែថាឃើញគាត់ស្រលាញ់អញ្ចឹងទៅហើយមិត្តភក្ដិម៉ែឪហ្នឹងអីវ៉ាន់ថាអត់លុយជូនយើងតិចតួច រៀងល្មមៗទៅ!!

ក៖  តែពេលរៀបការហ្នឹងពេលបែកប៉ុល ពតហើយបានរៀបការមែនអ្នកមីង?

ខ៖  បែកប៉ុល ពតហើយ។

ក៖  បានរៀបការហ្នឹង?

ខ៖  ហ្នឹងហើយ។

ក៖
ចាំ!!មីងពេលការហ្នឹងគេមានថ្លៃជំនូនអីអោយដែរតើហេ!!ថ្លៃទឹកដោះហ្នឹងអីវ៉ាន់អញ្ចឹងណាស់??

ខ៖ ចាំ ជូនដែរតែតិចតួច!!

ក៖  ហ្នឹងហើយតិចតួចគ្រាន់តែរៀបការអីអញ្ចឹងទៅណោះ?

ខ៖  ចាំហ្នឹងហើយ អត់គាត់អត់ដែរ!

កៈ
ហ៊ីៗ!!ចាំអ្នកមីងអើរសំរាប់លោកពូគាត់ជាមនុស្សយ៉ាងម៉េចចរិករបស់ស្វាមីរបស់អ្នកមីងអញ្ជឹង
ណាស់?

ខៈ ថាគាត់មុនទៅគាត់អត់ទាន់ពិការជើងគាត់ដើររែកដីរែកអីទៅធ្វើការធ្វើអីអោយគេ!!កៈ
ចា៎!!ខៈ មិនដែលផ្ទះទេ!!

កៈ ចា៎!!

ខៈ ឃើញគេរែកដីសែងដីគាត់ទៅសុំចែកគេមួយឡានរែកធ្វើ!!

កៈ ហ្នឹងហើយ !!

ខៈ ព្រោះអីអត់លុយចាយ ។

កៈ ចា៎!!

ខៈ ដើរតែសួរគេដែរហ្នឹង !! កំសត់ណាស់ប្តីញ៉ុម!!

កៈ ចា៎!!

ខៈ ដើររែកដីរែកអីធ្វើនេះ!!មិនដែលនៅផ្ទះទេ!!

កៈ ចា៎
អូយអញ្ជឹងមិនមែនស្រួលប៉ុន្មានដែរជីវិតរបស់គាត់ហ្នឹង!!អ្នកមីងនិយាយមើលប្រវត្តិម៉េចបាន
ស្លាប់ ញ៉ុមឮអ្នកមីងនិយាយប្រាប់ដំណាលហា៎!!!

ខៈ អញ្ចេកអើរគាត់កាលពេលពីមុនមកគាត់អត់ឈឺអីទេ គាត់ឈរមុខហ្នឹង គេហ្នឹងគេបើម៉ូតូ
ហើយគាត់ឈរបែរមុខទៅណោះហា៎!!បើកលឿនហា៎!!ហើយវាមកពីការបងប្អូនវាជីដូនមួយយ!
!

កៈ ហើយស្រវឹងមីងហេ?

ខ៖  ស្រវឹង !!
ស្រវឹងអញ្ចឹងវាបើកលឿនវាបើកមកវារហើយអូសគាត់អញ្ចឹងទៅដល់មុខផ្ទះបងជីដូនមួយម៉េចហ្នឹង!!

ក៖ ចាំ!!

ខ៖ ផ្ទះទល់មុខផ្ទះអាជ្រៀចហ្នឹង!

ក៖  ឆ្ងាយហ្នឹងអ៊ីចឹងមីង?

ខ៖  ចាំ ដល់ពេលទៅញ៉ុមក៏អត់ដឹងដែរ ញ៉ុមទៅបំរើប្អូនញ៉ុមមីមួយនៅភ្នំពេញហ្នូ!!វាកូនខ្ចី ដល់នេះទៅ វាបានបានដេកបានកន្លះខែ កន្លះខែដល់ពេលនេះទៅបងជីដូនមួយថាអញ្ចេក ង៉ែងអត់ដឹងប្ដីង៉ែងម៉ូតូបុកទេហេ?ញ៉ុមទឹមតែដាក់ខ្លួនដេកអញ្ចឹងយើងម៉ោង៧ម៉ោងអីហ្នឹងហាំ!! ដល់នេះគាត់តេទៅ ថាម៉ែហ្អែងម៉ូតូបុកហើយ មក ហើយថាឥឡូវទៅពេទ្យណា ទៅណោះទៅពេទ្យរុស្សីទៅចាំញ៉ុមទៅហើយចេញយកគាត់ទៅពេទ្យ ហើយអស់ច្រើនណាស់មីអូនអើយគ្រាន់តែចាក់ថ្នាំនៅក្នុងមន្ទីរពេទ្យហ្នឹងជា ហើយទិញថ្នាំផ្សារតាប៉ាងហា!!មួយអាទិត្យ៨០រៀល មួយអាទិត្យ៨០រៀល។ក៖ ហ្ហូ!!ខ៖ មួយអាទិត្យ៨០រៀល។

ក៖ ចាំ!!

ខ៖ តែគ្រាន់តែថាយើងទៅដាក់អាជើងហ្នឹងហាំណទៅដាក់ម្ដង៣០០(ដុល្លារ) ដាក់ដែកហាំ!!

ក៖ ហ្នូ!!

ខ៖  ដំបូងហាំ
ហើយដាក់ដំបូងទៅវាជាប់ហើយដល់ពេលវាដុះសាច់ដំបូងអាគៀនៗហ្នឹងពេលពេទ្យថាដុះសាច់ល្អណាស់កុំកាត់អី!!ស្ដាយ!! ញ៉ុមថាដុះតែសាច់ប៉ុន្ដែឆ្អឹងវាអត់ដុះ ដល់ហើយប្ដីញ៉ុមថាកាត់ទៅមីអូន បើចេះតែដឹកង៉េកហ្នឹងដើរអត់កើតដដែលហ្នឹង!!

ក៖ ហ៊ីៗ!!

ខ៖ ដល់ពេលនេះទៅប្តីញ៉ុមហ្នឹងសំរេចកាត់ កាត់បានមួយអាទិត្យវាឆាប់ជា
ព្រោះយើងវាចាក់ថ្នាំល្អៗហាំ!!

ក៖ ចាំ!!

ខ៖ ដល់ដេកពេទ្យមួយឆ្នាំហើយហាំ!!

ក៖ ចាំ!!

ខ៖ កាត់បានមួយអាទិត្យហ្នឹងដល់នេះទៅសល់លុយ១០០០០ សល់លុយ១០០០០!!

ក៖ ១០០០០ដុល្លារ?

ខ៖ អត់ទេសល់លុយ១០០០០លុយខ្មែរយើងហ្នឹង!

ក៖ សល់តិចម្លេះញ៉ុមស្មានតែ១០០០០ដុល្លារ!!

ខ៖ ចុះព្រោះអីអញ្ចេកយើងដេកពេទ្យហាំវាអស់លុយហាំ!!ដល់ពេលទិញបាយគេហូបហាំ
ដល់នេះអង្វរម៉ូតូហ្នឹងគេថាហ៊ីតឡូវ យកពីញ៉ុម១៥០០០ទៅញ៉ុមខ្ចីគេអោយ
អង្វរគេទៅសំពះគេទៅពេទ្យនៅគៀនឃ្លាំងហ្នឹង ពេទ្យជើងសមប្បនិម្មិតហាំ!!

ក៖ ចាំអាជើងសិបម្បនិម្មិតហ្នឹង?

ខ៖ ចា!!!ហ្នឹងហើយទៅវាស់វែងជើងអង្វរគេ
អញ្ចឹងបានគេថាជូនជូនទៅញ៉ុមសំពះក៏សំពះដែរ!!ញ៉ុមអត់លុយទេ
មានលុយក៏ញ៉ុមមិនមែនអោយតែប៉ុណ្ណឹងដែរ។ក៖ ចាំ!!ខ៖ ទៅមកហ្ហ៎!! ហើយជូនទៅ
ទៅមកវាឆ្ងាយដែរតាំងពីពេទ្យរុស្សីទៅណោះណោះ!!

ក៖
ចាំ!!ហ្នឹងហើយមិនមែនជិតណា!!តែអ្នកមីងសាច់ឈាមមុខមាត់អីវ៉ាន់អត់សមអ្នកពីបាកទេណា
ស់!មើលទៅស្រស់ថ្លាម៉ងហាំ!!

ខ៖ ប៉ុន្តែញ៉ុមនិយាយទៅញ៉ូមអានេះ
ញ៉ុមហាំញ៉ុមនឹកឃើញថាអត់ញ៉ុមអំតសូវគិតច្រើនព្រោះអីញ៉ុមបើកថ្នាំពេទ្យរុស្សីរាល់តែខែ!

កៈ  មីងឈឺអីគេវិញ?

ខៈ  ញ៉ុមគេហៅនេះថាជំងឺផ្លូវចិត្ត!!

កៈ ហ្ហ៎!

ខៈ តាំងពីបងញ៉ុមធ្វើអោយមុតកន្ត្រៃហ្នឹងមកហ៎!!

កៈ  ហ្ហ៎ហ្នឹងមកពីប៉ះពាល់សរសៃក្បាលមីងណោះ?

ខៈ  ហ្នឹងហើយ ហើយដល់ពេលនេះទៅញ៉ុមទៅបើករាល់តែខែហ្នឹង ដល់ខែទៅ ដល់ខែទៅ!!

កៈ តែអត់អីទេមីង ធម្មតា និយាយអីធម្មតា អីធម្មតា!!

ខៈ  តែពេទ្យគេអត់អោយគិតច្រើន។

កៈ ហ្ហ៎ !!

ខៈ គេអត់អោយយើងគិតច្រើនទេ កេអោយយើងសប្បាយៗហ៎មីអូនណាស់!!

កៈ ចា៎!!

ខៈ គេអត់អោយគិតច្រើនទេ ដល់យើងគិតច្រើនដល់ពេលយើងអង្គុយគិតលុយកាក់អីអញ្ចឹងអង្គុយគិតវាចេះតែចូលមកហើយណាស់!!ចេះតែអង្គុយគិតតៅណាស់ពេទ្យគេណែនាំយើងហ៎!!

កៈ ហ៊ឺៗ!!

ខៈ ហើយបើថាគិតអត់បានការដដែលហ្នឹងគិតធ្វើអី មិនបាច់គិតទេ គិតតែសប្បាយទៅ!!

កៈ ចា៎!!

ខៈ យើងសប្បាយ!!

កៈ  ហ្នឹងហើយ បើគិតពិបាកដដែលមីងទៅគិតធ្វើអីគិតទំរាំតែឈឺ!!

ខៈ  ចា៎!!

កៈ តែឈឺមិនមែនស្រួលឯណា ពិបាកតែខ្លួនយើងហ្នឹងមីងហាំ!!

ខៈ ចាំហើយពេទ្យគេប្រាប់អញ្ចឹងគេថាមិនបាច់គិតច្រើនទេ!!
ហើយញ៉ុមកាលមុនញ៉ុមចេះតែគិតអញ្ចឹងហាំ!!ដល់តែទឹមតែទៅបើកថ្នាំប៉ុន្មានឆ្នាំហ្នឹងដល់នេះ
ទៅគេអត់អោយយើងគិត ដល់ពេលឥឡូវញ៉ុមខ្ជិលគិតណាស់!!

កៈ ចាំ!!

ខៈ មានប៉ុន្មានញ៉ុមហូបប៉ុណ្ណឹងទៅ!!

កៈ ហ្នឹងហើយ !! ហើយអ្នកមីងអ្នកដែលបុកប្តីរបស់អ្នកមីងហ្នឹង គាត់មានជួយអីអត់?

ខៈ គេជួយ១០០ គេជួយ១០០អ្នកបុកហ្នឹងងាប់។

កៈ ហ៊ឺងាប់បណ្តោយ!!

ខៈ ហ្នឹងទៅពេទ្យជាមួយគ្នា។

កៈ ហ៊ឺ!!

ខៈ គ្រាន់តែទៅពេទ្យប្តីញ៉ុមចូលថតមុនណាស់ គេអោយវាចូលថតមុន
វាត្រឹមតែអាយុប្រហែលជា៣០អោយប្តី ដល់ពេលនេះហើយគេអូសវាចូលថត អូស
ថតហើយចេញមកវិញវាក្អកធ្លាក់ឈាម!!

កៈ ស្លាប់ទៅ?

ខៈ ស្លាប់ទៅ!!ស្លាប់ម៉ោង១១យប់។

កៈ គាត់ជិះតែម្នាក់ឯងទេអីចឹងហេ?

ខៈ ជិះតែម្នាក់ឯង បើកលឿនម៉ងហាំ!!

កៈ អូយ!!

ខៈ វាស្រវឹងហាំ!!

កៈ ហ្នឹងអញ្ចឹងហាំមីងហាគេនិយាយថាគ្រឿងស្រវឹងចូលខ្លួនអញ្ចឹងមីងហាំ និយាយទៅអាពេលផឹកស្រាហាគឺថាដេកទៅកុំជិះម៉ូតូអី អញ្ចឹងធ្វើបាបតែខ្លួនឯងហ្នឹង!!!

ខៈ ប្តីញ៉ុមកុំតែអញ្ចឹងកុំអីញ៉ុមថាអត់អីទេ!!

កៈ ហ្នឹងហើយ គាត់មាំទាំតើមីងហីមុននឹងគាត់ស្លាប់?

ខៈ ហ៊ីមានអី!!

កៈ ពេលមុនហ្នឹងគ្រោះថ្នាក់អីចឹងណាស់!!

ខៈ កាលមុនទាន់មានគ្រោះថ្នាក់ រៀងធាត់មានសាច់ឈាមហ្នឹង ថតរូបជាមួយហ្នឹងហិ!!

កៈ ចាំ!!

ខៈ រូបស្តេននេះហិ!!កៈ ចាំ!!ខៈ ហើយដល់ពេលនេះទៅគាត់មានសាច់គាត់មានអីដល់ពេលត្រឹមគេបុកហ្នឹងហិ គាងត់ធ្លាក់ខ្លួនស្គមទៅៗដូចថាវាត្រូវអីទៅវានេះទៅ ពេទ្យគេថាវាទៅជារបេង!!

កៈ ហ្ហូ!!

ខៈ មីអូនវាបុកអញ្ចឹងទៅវាគ្រាំក្នុង គាត់ស្គមតែររ៉ៃៗករដៃប៉ុនដងវែកហ្នឹង!!

កៈ អូយ!!

ខៈ ទូច ខ្យល់បក់ចង់រលំហ្នឹង។

កៈ ពេលមុនគាត់ស្លាប់ហ្នឹងហោ?

ខៈ ហ្នឹង!!

កៈ ក្លាយទៅជារបេងវិញមីងណោះ?

ខៈ ហ្នឹងវាដូចថាអញ្ចេកវា វាអាហ្នឹងដូចថាវាប៉ះពាល់ទៅសួតទៅអីអញ្ចឹងហាំមីអូនហា!!កៈ ហ្ហូ!!ខៈ កាលមុនអត់អញ្ចឹងផងហ្នឹង អត់ទេ ត្រឹមគេបុកហ្នឹងមក!!

កៈ  តែអាអ្នកបុកហ្នឹងគាត់ជិះតែម្នាក់ឯងតើហី?

ខៈ  ជិះតែម្នាក់ឯង តែគ្រាន់តែថាវាបើកទៅលឿន វាអូសយើងទៅផ្កាប់មុខហាំ!!កៈ ហ្ហ៎!!ផ្កាប់មុខ!!មីអូនឯងគិតមើល!!

កៈ ហ្ហ៎!អូសទាំងពីរនាក់យកទៅម៉ងអញចឹងទៅ?

ខៈ ហ្នឹងអូសគាត់ទៅ !!

កៈ  ហ៊ីខ្សៀតពេញមិនដឹងសាហាវខ្លំាងប៉ុណ្ណាទេមីងអើយ!!

ខៈ  ហ្នឹង ហើយញ៉ុមអត់ដឹងទេ ញ៉ុមនៅភ្នំពេញហ្ហ៎!!

កៈ ហើយពេលហ្នឹងមីងធ្វើផ្ទះធ្វើអីហើយនៅពេលហ្នឹង?

ខៈ  ញ៉ុមអត់ទាន់ធ្វើទេ!!

កៈ  ហ្ហ៎!!ព អញ្ចឹងប៉ុន្មានឆ្នាំហើយដែលស្វាមីអ្នកមីងគាត់ស្លាប់?

ខៈ  ទឹមតែចូល៦ ខែ៧ខែហ្នឹងទេ!!

កៈ  ហាទឹមតែស្លាប់ទេអញ្ចឹង?

ខៈ ទឹមតែស្លាប់តើ!!

កៈ  មើលមរណភាពរបស់លោកពូស្លាប់នៅក្នុងឆ្នាំ២០១៧ហ្នឹង នៅថ្ងៃអង្គារ៍ទី១៧ខែតុលាឆ្នាំ២០១៧ ហ្ហ៎ញ៉ុមស្មានតែយូរណាស់ហើយអញ្ចឹង!!

ខៈ  ទឹមតែស្លាប់តើ!!

កៈ  អញ្ចឹងផ្ទះហ្នឹងទឹមតែធ្វើតើមីងណោះ?

ខៈ  ទឹមធ្វើ!!

(កូន)៖ ទឹមធ្វើបាន២ឆ្នាំហ្នឹង!!

កៈ  ហាអ៊ីចឹងពេលហ្នឹងប្ដីអ្នកមីងគាត់បាននៅផ្ទះហ្នឹងហើយមែនទេ?

ខ៖  បាននៅ!!

ក៖  ហ្អ៎បាននៅមិនមែននេះទេ!!អ៊ីចឹងគាត់បាននៅហើយបានគាត់ស្លាប់!!

ខ៖  ដូចថាបាននៅដែរតែបាននៅតិចតួចទេ។

ក៖ ចា៎!!

ខ៖ ធ្វើហើយ!! និយាយទៅគាត់មិនដែលសំរានក្នុងទេ គាត់សំរាននៅកន្លែងទូរ!!

ក៖  សំរាននៅខាងក្រោយ!!

ខ៖  នោះនៅកន្លែងនោះ គាត់នៅហ្នឹងគាត់ចូលចិត្តល្វើយ។

ក៖ ចា៎!!មកពីទន្លេ!!

ខ៖  ក្នុងហាប់!!ហ្នឹងហើយ!!

ក៖  ចា៎ហ្នឹងហើយ!!ហាមីង ហាហ្អ៎មីងធ្វើបង្អួចតើ!!ស្មានតែអត់មានបង្អួត
តែអត់មានបង្អួចហាប់ហើយ!!អ្នកមីងសំរាប់ពេលបន្ទាប់ពីរៀបការជាមួយហ្នឹងលោកពូហើយអ្ន
កមីងមានកូនប្រុសស្រីប៉ុន្មាននាក់ដែរអ្នកមីង?

ខ៖  បានកូន៣។

ក៖  កូន៣ ស្រីប៉ុន្មានប្រុសប៉ុន្មានដែរអ្នកមីង?

ខ៖  ស្រី១ ប្រុស២!!

ក៖  ស្រី១ប្រុស២នាក់!!អាអូនពៅគេហី?

ខ៖  ពៅ!!

ក៖  ខ្ពស់ណាស់នេះ វែងដូចប៉ាម៉ងមិនស្រួលហា!!

(កូន)៖ប៉ាទាប!!

ខ៖  ប៉ាវាទាបទេ!!

កៈ ទាប!! តែម៉េចវែងម្លេ៎ះ?

ខៈ ហ្នឹង!!

កៈ ហេអ្នកមីងអោយហូបអីហេ អាចិកំបាំងអីហេ?

ខៈ អត់ដែលអោយហូបអី!!

កៈ តែអោយហូបធម្មតាអញ្ចឹងទៅមីងណោះ?

ខៈ អោយហូបធម្មតា មានស្អីអោយហូបមីអូនណ្ហើយ មានអី!!រកអីហូបអញ្ចឹង
បានបងជីដូនមួយគាត់ថា
វាស្រួលណាស់វាមានអីស៊ីហ្នឹង!!!!មានប្រហុកស៊ីប្រហុកមានអំបិលស៊ីអំបិល
ញ៉ុមខ្ជិលគិតណាស់!!

កៈ ចាំសប្បាយទៅមីង!!

ខៈ ដឹងគិតទៅមិនដឹតងបានអីមកពីណា!!

កៈ ហ្នឹងហើយ!!

ខៈ ខ្ជិល!!

កៈ
គ្រាន់តែថាគិតមួយថ្ងៃមួយថ្ងៃទៅថាទៅធ្វើការមានលុយប៉ុន្មានមកមានប៉ុន្មានហូបប៉ុណ្ណឹងទៅ!!

ខៈ ហ្នឹងហើយ!!ចាំញ៉ុមគិតអញ្ចឹង!!

កៈ បើមីងបើគិតទៅប៉ះពាល់សុខភាពដដែលហ្នឹងអីចឹងកុំគិតអី!!

ខៈ ចាំ!!

កៈ ចាំ!!

ខៈ ញ៉ុមអត់សូវគិតទេ!!

ក៖ ចាំ!!

ខ៖ ខ្ជិលគិតច្រើន!!អ្នកណាសួរញ៉ុមអ្នកណាសើច ញ៉ុមអត់គិតទេ!!

ក៖ ចាំ!!

ខ៖ ព្រោះថាញ៉ុមគិតក៏វាអត់ឃើញស្អី!!

ក៖ ហ្នឹងហើយ!!

ខ៖ បានផលប្រយោជន៍ដែរ!!

ក៖ ហ្នឹងហើយ កាត់ចិត្តបានល្អម៉ងអ្នកមីងហិ ទាញចិត្តខ្លួនឯងបានហាំ!!
អ្នកមីងកូនអ្នកមីងគាត់ឈ្មោះអីគេខ្លះ ៣នាក់ហ្នឹងគឺឈ្មោះអីគេខ្លះ?

ខ៖ មីបងហ្នឹងម៉ាលី!!

ក៖ ម៉ន ម៉ាលីហោ?

ខ៖ ចាំ!!ហា!!ឈួន!!

ក៖ ឈួនម៉ាលី!!

ខ៖ ចាំ!!បញ្ជីជាតិវាមានតើ!!មីអូនឯងមើល!

ក៖ ចាំអញ្ចឹងមើលនៅក្នុងសៀវភៅគ្រួសារ!! ចុះកូនទី២អ្នកមីង?

ខ៖ រដ្ឋា!!

ក៖ ចុះកូនទី៣?សំណាង!!

ខ៖ សំណាង!!

ក៖ ចាំអញ្ចឹងនេះនៅក្នុងសៀវភៅគ្រួសាររបស់អ្នកមីងអញ្ចឹងកូនអ្នកមីងឈ្មោះវៃសុម៉ាលី
ត្រកូលវៃទេ!!

ខ៖ ហ្នឹងហើយត្រកូលវៃ។

កៈ  កើតនៅក្នុងថ្ងៃទី០២ ខែ០៥ ឆ្នាំ១៩៩៥ នៅកោះគរហ្នឹងដែរ កូនទី២ឈ្មោះវៃ រដ្ឋា
កើតនៅក្នុងថ្ងៃទី១០ខែ០៧ឆ្នាំ១៩៩៨ នៅកោះគរហ្នឹងដែរ !!វៃ សំណាង កើតនៅក្នុងថ្ងៃទី២៨
ខែ០២ ២០០៣ នៅកោះគរហ្នឹងដែរ!!ហ៊ីតាមការពិតកូនអ្នកមីងក្មេងៗដែរហ្នឹងហោ?

ខៈ ចាំ!!

កៈ  ចាំ!អ្នកមីងរៀបការជាមួយពូនៅឆ្នាំណាវិញ?

ខៈ  ប៉ុន្មានផងភ្លេច!!

កៈ  ការ មីងអាយុបានប៉ុន្មានឆ្នាំបានរៀបការ ?

ខៈ  ញ៉ុមហេអាយុចូល២០ហើយ។

កៈ ចាំ ២០ជាងឡើងហើយមីងហោ?

ខៈ  ហើយញ៉ុមការគេស្រលាញ់ញ៉ុមញ៉ុមទៅពេលញ៉ុមអាយុ១៦ ១៧!!

កៈ ហ្ហ៎ហ្នឹងហើយបែក!!

ខៈ  ហ្នឹងហើយគេ!!

កៈ  អញ្ចឹងដល់ពេលមើលកើត៦៦(១៩៦៦)មក៨៦(១៩៨៦)អ្នកមីងបាន២០ឆ្នាំ
អ្នកមីង២០ឆ្នាំជាងបានរៀបការយូរដែរហើយហ្នឹង!!

ខៈ ហ្នឹង!!

កៈ ចង់៣០ដែរហើយហ្នឹង ញ៉ុម២៧ដែរញ៉ុមមិនទាន់រកគូឃើញដែរ!!
អ្នកមីងនិយាយពីជីវិតអ្នកមីងនៅក្នុងរបបសង្គ្រាមហាំរាជលន់ នល់
មីងចាំអីគេខ្លះអាពេលគេទំលាក់គ្រាប់បែកហ្ហ៎ ម៉េចទៅ?

ខៈ ហ្ហ៎ទំលាក់គ្រាប់បែកហោ!!
វាទំលាក់អីចឹងហើយពួកអាពតហើយញ៉ុមនេះហ្នឹងញ៉ុមនៅហើយញ៉ុមចេះតែដើររើសអី
រើសអីអញ្ចឹងទៅណាស់ ហ្វប ហើយក្មេងបង្រៀនហែលទឹកហ្នឹង គាត់កំលោះ!!

ក៖ ចាំ!!

ខ៖  រៀនហែលទឹក ហែលទឹក បង្រៀនហែលទឹក
មិនមែននិយាយច្រវ៉ែច្រវ៉ាចាប់អីមិនបានចាប់ពងគេ!! បើមនុស្សលង់ទឹកហើយហ្នឹងច្រវ៉ែច្រវ៉ា
ច្រវ៉ែច្រវ៉ាទៅចាប់ពងគេ។

ក៖  គេអាហ្នឹងអ្នកបង្រៀនហែលទឹក?

ខ៖  ហ្នឹងហើយបង្រៀនហើយញ៉ុមអត់ចេះហែលទឹកហ្នំ!!ហ្នឹងនៅក្នុងស្ទឹង!!

ក៖ ចាំ!!

ខ៖
ហ្នឹងញ៉ូមនៅពីអាពតញ៉ុមនិយាយទៅថាឃើញអាពតឃើញអីដែរតែញ៉ុមទៅខាងចុងស្មោរវាធ្វ
ដៃឬណាស់អូន!

ក៖ ចាំ!!

ខ៖
គ្រាន់តែថាម៉ាក់ញ៉ូមអញ្ចឹងគេអោយទៅធ្វើចុងភៅចុងអីអញ្ចឹងដាំបាយអោយគេហូបអញ្ចឹងទៅ!
!

ក៖ ចាំ!!

ខ៖  ញ៉ុមយ្យូរកំមែលហ្នឹងយ្យូរដាក់បាយអោយបងប្អូនញ៉ុមទៅ ញ៉ុមកំពង់តែដើរនេះហ្នំ!!

ក៖ តែអត់ទេអ្នកមីងពេលនេះហ្នំ!!នៅក្នុងលន់ នល់សិន
មីងធ្លាក់ឃើញគេទំលាក់គ្រាប់បែកអាប៊ឹងៗមកអីវ៉ាន់អីអត់?អាប៉ុមប៊ីអីវ៉ាន់ហ្នំ??

ខ៖ អត់ទេ!!

ក៖ មីងពេលលន់ នល់ មីងនៅកោះគរហ្នឹងដដែលឬក៏មីងផ្លាស់ប្ដូរទីលំនៅទៅនៅណាដែរ?

ខ៖  នៅ នៅកោះគរហ្នឹងដដែល!!

កៈ  ចាំ អ៊ីចឹងនៅនេះអត់មានទំលាក់គ្រាប់ទំលាក់អីត្រូវដែរទេហោមីងហោ?

ខៈ  មាន មានតើ អត់ចេះអត់ទេ!!ចូលត្រង់សេចូលអី!!

កៈ  ហ្នំហ្នឹងហើយ អាហ្នឹងមានហើយ!!

ខៈ  ចូលត្រង់សេជីកចូលត្រង់សេ ចូលត្រង់សេហើយអាហ្នឹង!!

(កូន)៖ ញ៉ុមនៅក្មេងញ៉ុមដឹងថាមានដែរ!!

កៈ  អ្នកណាគេប្រាប់? គេនិយាយប្រាប់ដែរកូនមីងហី!!

ខៈ  ចាំ!! ត្រង់សេ ហើយហ្នំ គ្រាប់ផ្លោង ផ្លោងណាស់!!

កៈ  សាហាវម៉េងមីងហោ?

ខៈ  ហ្នឹង!!

កៈ  មានដែលធ្លាក់ចំអ្នកណាគេហោ?

ខៈ  អត់ទេ គ្រាន់តែថាធ្លាក់មកហ្នឹង
មុខយើងអាដៅនេះហ្នឹងត្រង់សេហ្នឹងចំពីមុខអីអញ្ចឹងទៅណាស់!!

កៈ ហ៊ុៗ!!

ខៈ  គ្រាន់តែថាវាអត់អីទេ វានៅឆ្ងាយអីអញ្ចឹងទៅណាស់!!

កៈ ចាំ!!

ខៈ  បើវានៅជិតអីវាខ្ទៀតអំបែងចូលហើយ!!

កៈ  ហ្នឹងហើយ ពិបាកណាស់មីងណោះ?

ខៈ  ហ្នឹងហើយពិបាកណាស់!!

កៈ  ត្រូវចំត្រង់សេយើងអីវ៉ាន់ងាប់អស់រលីង!!

ខ៖  ហ្នឹង!!

ក៖  ងាប់អស់ម៉ង!!

ខ៖  ធ្លាក់ចំពីមុខ!!អំបែងខ្មៀតងាប់អស់ហើយ!!

ក៖  ចាំ!! និយាយទៅចូលនៅក្នុងហ្នឹងការពារមួយគឺកុំអោយវាឃើញមឹងណោះ?

ខ៖  ហ្នឹងហើយ!!

ក៖  តែឃើញហ្នឹងទំលាក់ត្រូវម៉ង!!

ខ៖  ហ្នឹងហើយ!!

ក៖ ចាំ!

ខ៖  ចុះកប៉ាល់ហោះ!!

ក៖  វាមានទៅស្គាល់មុខអី!!

ខ៖ ហ្នឹង!!

ក៖  តែឃើញមនុស្សៗហ្នឹងវាស្មានតែពួកខ្មាំង វាទំលាក់បឹង!!

ខ៖  ហ្នឹង!!

ក៖ ហ្នឹងហើយ អ៊ីចឹងអ្នកមីងចូលដល់ជំនាន់ប៉ុល ពត អ្នកមីងថ្ងៃដំបូងពេលចូលសង្គ្រាមប៉ុល ពតម៉េចដែរ?

ខ៖  ពេលយើងរត់ទៅយើងដើររហូត អើយដើរឆ្ងាយណាស់ទំរាំតែទៅដល់ស្ពោរ ដូចថាដើរទៅឯជីតជួបផ្ទះខ្មោចជួបផ្ទះអីអញ្ចឹសឯទៅចេះតែដេកគៀនៗហ្នឹងទៅ ទាំងអស់គ្នា!!

ក៖  ហ៊ីចាំ !! ទាំងគេទាំងយើងមឹងណោះ?

ខ៖  ចាំ!!ហ្នឹងហើយទាំងគេទាំងយើងទាំងរ៉ូង ដើរ!!

ក៖  វាអស់ខ្លាចអស់អីហើយមឹងណោះ?

ខ៖ អត់ខ្លាចហើយអោយតែរស់។

ក៖ ចាំ!!អ្នកមីងពេលថ្ងៃសង្គ្រាមដំបូងហាំ គេជំលៀសពីកោះគរហ្នឹងទៅមីងហេ?

ខ៖ ចាំ!!

ក៖ ហើយទៅនៅណាវិញទៅមីង?

ខ៖ រហូតចុងស្តោរតាប៉ែនហ្វ៎!!ញ៉ុម!!

ក៖ នៅណាទៅ? គេជំលៀសទៅលើណោះឬក៏ទៅក្រោមវិញ?

ខ៖ ញ៉ុមឡើងទៅលើ!!

ក៖ ហ្វ៎!!!

ខ៖ ទៅស្រុកតាហ្នឹងគាត់នាំទៅទៅស្រុកគាត់។

ក៖ ចាំ!!

ខ៖ បានទៅស្រុកគាត់ហ្នឹងបានរស់!!បើនៅនេះបែបអត់រស់ទេ !!

ក៖ តែអ្នកខ្លះមីងភាគច្រើនទៅខាងក្រោមទៅសំប៉ាន់ ទៅកោះធំទៅអីអញ្ចឹងទៅណាស់!!

ខ៖ ញ៉ុមទៅរហូតចុងស្តោរស្រុកតាហ្នឹងឆ្ងាយណាស់!!

ក៖ មីងម៉ាសង្គ្រាមប៉ុល ពតហ្នឹង នៅហ្នឹងរហូតម៉ងឬក៏យ៉ាងម៉េច?

ខ៖ ហ្នឹងញ៉ុមទៅនៅហ្នឹង រហូតហ្នឹង ដល់ពេលយើងបែកហើយយើងមកវិញ!!ក៖ ហ្វ៎!!ខ៖ មកមកហ្នឹងនៅបាត់ដំបង ។

ក៖ នៅបាត់ដំបងសិន!!

ខ៖ ហ្នឹងហើយដល់បាត់ដំបងហើយដល់បងប្អូនខាងប៉ាប៉ុនផឹកពេកម៉ាក់ញ៉ុមគាត់មកចោលគាត់ថាអត់នេះទេទៅហ្បែងដីធ្លីអីហ្នឹងហ្បែងយកអញទៅហើយ
ប៉ុនផឹកពេកព្រោះអីផឹកមកគេមកទារលុយគាត់ផឹកមកមកទារលុយគាត់ !!

កៈ ចាំ!!

ខៈ ហើយគាត់មានលុយមកពីណាបើផឹកលលាតែហ្នឹង!!
ហើយដល់នេះទៅគាត់ថាអញទៅស្រុកហើយ ហ្អែងនៅហ្នឹងទៅ!!

កៈ ចាំ!!

ខៈ ដល

តែគាត់មកមកដែរ!!

កៈ ហ៊ី!!អ្នកមីងនិាយយពីជីវិតរបស់អ្នកមីងឆ្លងកាត់នៅក្នុងរបបប៉ុល
ពតអ្នកមីងពិបាក់ម៉េចខ្លះមីងនិយាយរៀបរាប់អោយអស់មើល?

ខៈ ញ៉ុមអញ្ចេកពេលក្មេងហ្នឹង ញ៉ុមពីអាពតហ្នឹងញ៉ុមទៅកាប់ធាងខេត្រម្តង
ដល់កាប់ម្តងអ៊ីចឹងញ៉ុមដូចថាឈប់ទៅកាប់ហើយ ញ៉ុមឈប់ទៅកាប់ញ៉ុមអត់អីដែរ!!

កៈ ចាំ!!

ខៈ ទៅខាងហ្នឹងវាអត់សូវអីទេ!!

កៈ គេលើកលែង លើកលែង!!

ខៈ ហ្នឹងហើយ អត់សូវអី គេលើកលែង គ្រាន់តែថាយើង!!

កៈ (គាត់រវល់លើកទូរសព្ទ័) អ៊ីចឹងមីងមីងនិយាយរៀបរាប់ពីអ្នកមីងនៅជំនាន់ប៉ុល ពតទៀត?

ខៈ កាលពេលអាពតញ៉ុមទូលបាយអោយបងប្អូនហូប
ហើយញ៉ុមដើរអញ្ចឹងហើយញ៉ុមចេះតែដើរទៅ!!

កៈ ហ៊ីៗ!!

ខៈ ហើយនិយាយពេលអាពតគេទំលាក់សសរត្រូវញ៉ុមហាំ!!ចំក្បាលហ្នឹងនេះ!!

កៈ អូយ!!

ខ៖ នេះស្នាម នេះដុះសក់ហើយនេះ!!

ក៖ នៅហ្នឹងម៉ងមីងហោ?

ខ៖ ហ្នឹង!!

ក៖ អញ្ចឹងចឹបានអ្នកមីងប៉ះពាល់ផ្លូវចិត្ត
អាត្រូវកន្ត្រៃមួយហើយត្រូវអាហ្នឹងមួយទៀតអ្នកមីងណោះ?

ខ៖ ហ្នឹង ពេលអាពតញ៉ុមង្វតទឹកហាំ!!

ក៖ ហ៊ឺ!!

ខ៖ ហើយដល់នេះទៅត្រូវអាសរសរគេអាសសរលុចហ្ន៎!! ធ្លាក់ទៅកប់នៅនឹងទឹកហ្នឹង!!

ក៖ អូយអត់មានលង់អីទេអ្នកមីងហោ?

ខ៖ ហើយ ឡើងហើមប៉ោងម៉ាក់ញ៉ុមថា
ញ៉ុមញ៉ុមកូរខ្ទុះហាំ!!កូរវាឈឺណាស់គេហៅថាខួរអណ្តែងហ្ន៎!!

ក៖ ចាំ!!

ខ៖ ដល់នេះទៅញ៉ុមឃំម៉ាក់ញ៉ុមថា ហ៊ឺអញយកថ្នុងត្រីយកជូស ជូសហាំលឺតែផូស!!

ក៖ អូយ!!

ខ៖ ហ្នឹងគាត់មើល!!

ក៖ ដល់ពេលហើយវាចេញអញ្ចឹងទៅមីងណោះ?

ខ៖ ចាំ តែគ្រាន់តែថាវាអត់ដុះសក់ហាំ!!

ក៖ ចាំ!! ហាវាជួសមកវា វាដំបៅធំមែនហ៊ីអីមីង?

ខ៖ អំបៅប៉ុននេះ!!

ក៖ ហ្ន៎!!

ខ៖ វាឡើង វាហើមនៅហា៎!!

ក៖ ចា!!

ខ៖  ដល់នេះទៅវាអត់ដុះសក់!!

ក៖  ហ្នឹងហើយអញ្ជឹងក៏នេះទៅ!! មីងការហូបចុកអ្នកមីងពេលនៅក្នុងជំនាន់ប៉ុល ពតហ្នឹង?

ខ៖  នៅក្នុងជំនាន់ប៉ុល ពត ញ៉ុមហូបបបរវាវកខ្លួកហ្នឹង!!

ក៖  មានរកអ្វីផ្សេងហូបបានក្រៅពីបបរហ្នឹងទេអ្នកមីង?

ខ៖ ចា៎!! ដល់នេះទៅអញ្ជឹងទៅញ៉ុមទៅកន្លែងម៉ាក់ញ៉ុមទៅរកបាយរកអីអញ្ជឹងទៅ!!ក៖ ហ៊ីៗ!!ខ៖  មកបានហូបតិចៗអញ្ជឹងទៅ!!យកអោយបងអីខ្លះ!!

ក៖ ចា៎!

ខ៖ អញ្ជឹងទៅញ៉ុមដើរជញ្ជូន!!

ក៖  អញ្ជឹងបានយកបាយយកអីអោយបងដែរ?

ខ៖ ចា៎!!

ក៖
ដោយសារពេលមុនអ្នកមីងបានប្រាប់ថាម្តាយអ្នកមីងបានដាំបាយអោយពួកហ្នឹងអ្នកមីងហោ?

ខ៖  ហ្នឹងហើយ!! គេអោយទៅធ្វើដាំបាយដាំអី!!

ក៖ អញ្ជឹងក៏បានម្ហូបអាហារហូបអីចឹងទៅមីងណោះ?

ខ៖ ហ្នឹង!!គ្រាន់តែថាអានេះទៅគ្រាន់តែអោយគ្រាន់តែលួចលាក់អោយកូនហ្នឹងហា៎!!

ក៖  តែក៏មិនបើកចំហរដែរ !! តែបើចំហរក៏ត្រូវ!!

ខ៖  ហ្នឹងហើយរបស់គេ!!

ក៖ ចា៎!!

ខ៖ ហ្នឹងហើយដល់ពេលហើយគាត់អោយហូបហើយតិចតួចហ្នឹងចេះតែយូ្សរមក!!

ក៖
ហ៊ឺៗ!!អ្នកមីងមានដែលឃើញគេយកមនុស្សគេយកទៅសម្លាប់ចោលនៅក្នុងជំនាន់ហ្នឹងទេ?

ខ៖ ឃើញតែចិនៗ!!

ក៖ ម៉េចទៅអ្នកមីង?

ខ៖ វាលួចអីអឺចឹងទៅ វាចងសេកយកទៅវៃចោល។

ក៖ ជនជាតិចិនមីងហោ?

ខ៖ ហ្នឹងហើយ ចិន ខ្មែរយើងហ្នឹង !!

ក៖ ចាំ!!

ខ៖ គេចង គេលួចស្អីគេគេ ខ្មែរយើងដែរហ្នឹង លួចប្រហុកលួចស្អីគេគេ គេឃើញ!! ប្រហុក អំបិល អង្ករអី ឃើញគេចាប់ចង ចាប់ទៅ ចងហើយបណ្តើរ ចងសេកទាក់យកទៅ អាហ្នឹងទាក់យើងមួយៗទាក់ដូចប្រឡាយគោអញ្ចឹងណាស់!!ចងអញ្ចឹងទាក់មួយៗគេយកវៃចោល!!

ក៖ ចាំ មីងដែលឃើញគេមុខឰអីអត់
ដែលឃើញមុខនឹងភ្នែកឰនឹងត្រចៀកអីទេអារឿងសម្លាប់ចោលហ្នឹង?

ខ៖ វាដូចថាឃើញ អាខ្លះឃើញអាខ្លះអត់អញចឹងទៅ!!ហើយបើញ៉ូមអាពតរើស!!

ក៖ ម៉េចវិញទៅមីង?

ខ៖ អាពតហ្នឹងនិយាយខ្មែរយើងហ្នឹង សក់ត្រឹមកញ្ចឹងករយើងហ្នឹងស្តើងខ្ពស់
ចូលក្នុងកាស៊ីនបាយកាស៊ីនអីហ្នឹងដើរចូលចេញចូលអីហ្នឹង!!

ក៖ ចាំ!!

ខ៖ គ្រាន់តែថាវាមិនធ្វើអីយើងដែរណាស់ ព្រោះយើងអត់ទៅលួចអីលួចអីរបស់វា!!

ក៖ ហ៊ឺៗ!!

ខ៖ វាអត់យកយើងទៅវ៉ៃចោលវ៉ៃអីទេ!!

ក៖ ទ័ពប៉ុល ពតវានៅហ្នឹងច្រើនម៉ងមីងហេ?ខ៖ ហ្នឹង!!ក៖ វាមើលតាមភូមិឃុំអីអញ្ចឹងហាំ?

ខ៖ ហ្នឹង!! ហ្នឹងវាដើរមើលវាដើរចល័តអីអញ្ចឹងណាស់!!ហ្នឹងហើយ!!ក៖ ចាំ!!ខ៖ វាចេញចូលក្នុងកាស៊ីនបាយ ថាយើងមានអីមាននអីអញ្ចឹងទៅណាស់ ដើរប្រមែប្រមូលអីអញ្ចឹងទៅ បើអាណាធ្វើអាក្រក់អញ្ចឹងវាយកទៅវ៉ៃចោលទៅ!!

ក៖ ចាំ!! តែអ្នកមីងពេលហ្នឹងនៅកាប់ផាងខេត្រ ជាកុមារនៅឡើយទេមីងណោះ?

ខ៖ នៅកុមារ!!

ក៖ ដោយសារទឹមតែ១០ឆ្នាំ!!

ខ៖ ញ៉ុមនៅទូចដែរហ្នឹង!!ក៖ ចាំ!!ខ៖ ពេលអាពត។

ក៖ អ្នកមីងម្ដាយអ្នកមីងអត់អីណាប៉ុន្មានដែរហេ គ្រាន់តែដាំបាយហ្នឹង អត់មានធ្វើអីស្ទូងដកអីហ្នឹងគេទេមីងហេ?

ខ៖ អត់!! តែគ្រាន់តែនេះអញ្ចឹងទៅ កាលមិនទាន់ធ្វើអីហ្នឹងគាត់ទៅធ្វើការធ្វើអីហ្នឹងគេដែរហ្នឹង តែដូចថានេះគេដកគាត់មួយអីអញ្ចឹងមក!!ពីរនាក់អោយជួយមកធ្វើស្លរ!!

ក៖ ដាំបាយ!!

ខ៖ ហ្នឹងហើយ!!ធ្វើអោយពួកគាត់ស្ទូងហ្នឹងអីចឹងទៅ។

ក៖ គាត់ទៅយកអង្ករ បើកអង្ករអីមកពីកន្លែងគេបើកហេ?

ខ៖ អាហ្នឹងគេយកមកអោយយើង!!

ក៖ ធ្វើអីអញ្ចឹងទៅណោះមីងណោះ?

ខ៖ ហ្នឹងហើយ!!

កៈ ចាំ!!

ខៈ យើងមានទៅបើកអីគេយកមកអោយហ្នឹង។

កៈ ចេះតែធ្វើតាមគេទៅ ហើយដួសអីអោយពិបាកអីចឹងហាំ!!

ខៈ ហ្នឹងហើយ!!

កៈ ពេលខ្លះអ្នកដាំបាយក៏គ្នាចិត្តមិនស្រួលដែរ !!

ខៈ ហ្នឹងហើយ!!

កៈ ឃើញបន្តិចមកអីចឹងហ្វាំ!!

ខៈ ហ្នឹង!!

កៈ ហើយអោយខ្មែរគ្នាឯងហូបបានបន្តិចតែមួយហ្នឹង!!

ខៈ ហ្នឹង!! បើមួយខ្ទះអង្ករពីរកំប៉ុងហ្នឹង ទឹករាវកខ្វក!!

ក ៈហ្នឹងហើយ ហើយកាប់បន្លែកាប់អីលាយអីចឹងទៅមីងហោ?

ខៈ ហ្នឹង!!

កៈ ដូចជ្រូកហើយពេលហ្នឹងមីងហោ?

ខៈ ហ៊ីគាស់គល់ចេក គល់ចេកយើងហ្នឹងមីអូន!!

កៈ ចាំ!!

ខៈ គាស់ស្មោរដូចដំឡូងហូបទៅ អោយតែឆ្អែតៗទៅ!!

កៈ ចាំ!!

ខៈ គល់ចេកហ្នឹង!!

កៈ ពេលហ្នឹងនៅឯណាក៏សំបូរដែរ អាចេកគល់ចេកហ្នឹងអ្នកមីង!!

ខ៖ ហ្នឹង!! គាស់ស្មោរ គាស់ស្មោរ តែឥឡូវយើងហូបអត់កើតទេណាស់!!

ក៖ ចាំ!!

ខ៖ ចាំ ពីអាពតចេះតែហូបទៅគាស់ស្មោរ កាប់ចេកអីចោលអញ្ចឹងគាស់ទៅ។

ក៖ អ្នកមីងបន្ទាប់ពេលបែកជំនាន់ប៉ុល ពតមក មួយៗមានអារម្មណ៍ម៉េចដែរ អ្នកមីងអីវ៉ាន់គ្រួសារអីវ៉ាន់អញ្ចឹងណាស់?

ខ៖ ពិបាកវេទនាណាស់មីអូនអើយ!!

ក៖ ដូចថាពេលបែកទៅមានអារម្មណ៍សប្បាយចិត្តអីអត់ដោយសារផុតពីសង្គ្រាមហ្នុ៎?

ខ៖ ថាវាសប្បាយដែរដូចថាវារួចពីទុក្ខមកអាហ្នឹងហាំ!!

ក៖
ចាំ!!ហើយពេលហ្នឹងឮមីងនិយាយប្រាប់ញ៉ុមពេលមុនហ្នុំថាឪពុកបានសុំផ្លូវម្ដាយបែកគ្នាអញ្ចឹងទៅពេលជំនាន់ប៉ុល ពតហ្នឹងទៅ!!

ខ៖ ចាំ គាត់ចង់ថាអញ្ចេកគាត់ទៅផ្សេងកុំអោយទៅជាមួយគ្នា លោរគាត់ទៅផ្សេងគាត់រស់ម៉ាក់ញ៉ុមទៅផ្សេងហ្នឹងគាត់រស់អញ្ចឹងទៅណាស់!!

ក៖ ហ៊ឺៗ!!

ខ៖ អានេះគាត់គាត់ស្មានក្នុងចិត្តគាត់ គាត់ចង់ធ្វើអញ្ចឹង!!

ក៖ តែគាត់ទៅជាអ្នកស្លាប់វិញទៅ?

ខ៖ ហ្នឹងហើយ!!

ក៖ ដោយសារបើសិនជាគាត់នៅរស់ ក៏គាត់មករកកូនប្រពន្ធដែរអ្នកមីងហោ?

ខ៖ ចាំ!!មករក តែគាត់ស្លាប់បាត់ហើយ!!

ក៖ អ្នកមីងសំរាប់ជីវិតរបស់អ្នកមីង
អ្នកមីងរកស៊ីអីគេខ្លះនៅក្នុងជីវិតហាំ!!ធ្លាប់រកស៊ីអីគេខ្លះដែលតាមចាំមកហាំ?

ខ៖  ញ៉ុមហោ?

ក៖ ចាំ!!

ខ៖  ញ៉ុមមានតែដើរធ្វើការធ្វើអីអោយគេហ្នឹង ។

ក៖  មើល ឥឡូវកាត់ផ្ទីអោយគេមីងហោឥឡូវ?

ខ៖  ចាំ កាត់ផ្ទី!!

ក៖  ចុះពីពេលមុនមកធ្វើអីគេវិញ?

ខ៖  ញ៉ុមធ្វើស្មៅអោយគេ!!

ក៎ ចាំ មានដែលមានចំការដាំស្រូវដាំស្រែខ្លួនឯងអីអត់?

ខ៖  អត់!! កាលមុនញ៉ុមធ្វើស្រែធ្វើស្រូវដែរ ដល់តែពេលដីតែបន្តិចហ្នឹង
អាំញ៉ុមអីវ៉ាន់ហ្នឹងលក់ចែកលុយគ្នា!!

ក៖ ចាំ!!

(មិត្តភក្តិ)៖លក់បានថ្លៃទេកាលហ្នឹង?

ខ៖  ចាំ?

(មិត្តភក្តិ)៖ បានថ្លៃទេ?

ខ៖  បានថោកហ្នឹងហោ!!!

(មិត្តភក្តិ)៖ ចំបក់មុនថោក។

ខ៖  ចាំ!!

ក៖  អូនអូនដែលធ្លាប់ឃើញម៉ាក់ធ្វើអីគេផ្សេងទៀតអីអត់?កូន!!

(កូន)៖ អត់ដែល!!

កៈ អត់ដែលទេ អ៊ីចឹងដល់ពេលធំដឹងក្ដីមកនៅជាមួយម៉ាក់ម៉ាក់ធ្វើអីខ្លះ?

ខៈ មកមានអី មកមានធ្វើអីទេ!!វាអត់មានដឹងទេ មានតែញ៉ុមដើរធ្វើស្មៅធ្វើអីអោយ
ពេលមុនវាអត់ទាន់ដឹងទេ!!!

កៈ ហ្ហ៎!!ទឹមតែធំឥឡូវហ្នឹងដែរហ្នឹង!!

ខៈ ចា៎!

កៈ កើត២០០០ជាងហ្នឹងអ៊ីចឹងហ្ហ៎!!

ខៈ ចា៎ កើតមានទាន់អាពតអី!!

កៈ ក្មេងជំនាន់ឥឡូវមីងណោះ??

ខៈ ចា៎!!

កៈ មីងជំនាន់ហាតាមចំនង់ចំនូលចិត្តរបស់អ្នកមីង
អ្នកមីងចូលចិត្តពិសារហូបអីគេដែរអ្នកមីង?

ខៈ ចា៎?

កៈ ចូលចិត្តម្ហូបអី?

ខៈ ញ៉ុមអើរឆាខ្ញី ម៉ាក់ញ៉ុមចូលចិត្តឆាខ្ញីថ្លើមជ្រូកថ្លើមអីហ្នឹង!!កៈ ហ្ហ៎!!

(កូន)ៈ យាយញ៉ុមចូលចិត្តតែឆាខ្ញី សាច់ជ្រូកចៀន ចៀនប្រៃកាលណាល្អកាលហ្នឹង!!

កៈ អើយពិបាកលេបណាស់!!

ខៈ ដូចថាអត់សូវចេះហូបផ្អែម!!

កៈ ចា៎!!

ខៈ ហើយកាត់មកញ៉ុម ញ៉ុមអត់ចេះហូបផ្អែម !!

កៈ ចូលចិត្តហូបប្រៃ!!

ខ៖  ប្រៃល្មមទៅប្រឡាក់ទៅ
ហើយញុំមអញ្ចេកដូចថាវារៀងអន់អញ្ចឹងទៅដាក់អំបិលវារៀងជ្រុលឡើងប្រៃ!!

ក៖  ហ៊ើៗ!!គាត់ចូលចិត្តប្រៃវិញម្ដាយរបស់អ្នកមីង!!អ្នកមីង!!

ខ៖  ម៉ាក់ញុំមចូលចិត្តណាស់ ចៀន អាំងញុំមនៅជាមួយគាត់អត់សូវដែរសូវស្លរទេ!!

ក៖ ហ្ន៎ចូលចិត្តក្រៀមក្រោះជាង!!

ខ៖ ចា៎»!!!ចូលចិត្តក្រៀមក្រោះ ហើយបើថាត្រីវិញបើថាអាំងហា៎
អាំងហើយអត់ក្រៀមអត់អីហា៎គាត់អត់ហូបទេ!!

ក៖ ហ៊ើទាល់តែក្រៀម !!

ខ៖  គាត់ថាឆ្អាបណាស់ គាត់រើសណាស់ ត្រីជំរីត្រីអីគាត់អត់ហូបទេ!!

ក៖  អ្នកមីងចូលចិត្តពណ៌អីគេជាងគេ?

ខ៖ ចា៎??

ក៖  ចូលចិត្តពណ៌អី?

ខ៖  ពណ៌អីទេ!!

ក៖  ពណ៌អ្នកមីងស្រលាញ់ពណ៌អីជាងគេ?

ខ៖ ពណ៌អី?

ក៖  ពណ៌ដូចពណ៌លឿង ពណ៌ខៀវ ពណ៌បៃតង អីអញ្ចឹងទៅណាស់
អ្នកមីងចូលចិត្តពណ៌អីគេជាងគេ?

ខ៖  ខោអាវហោ?

ក៖  ហ្នឹងហើយ!!

ខ៖  ញុំមហោបើចូលចិត្តអាវពាងក្រហម ពាងផ្កាឈូក។

ក៖ ហ្នឹអញ្ចឹងណោះមីងណោះ?

ខ៖ ចាំ!!ហើយញ៉ុមមិនមែននិយាយអីទេ
ញ៉ុមចំណាស់នេះក៏ដោយខោអាវអីទិញមកអីរៀងចំណាស់ អីញ៉ុមអត់ចូលចិត្តទេ!!

ក៖ ចង់តែក្មេងអ្នកមីងណោះ?

ខ៖ ចង់ស្លៀកខោអាវក្មេងៗញ៉ុមអត់ចង់ពាក់អាវមនុស្សចាស់ម៉ង។

ក៖ ចាំ!!

ខ៖ ញ៉ុមអញ្ចឹងណាស់ ក្មួយញ៉ុមអីក៏ដោយបើទិញខោអាវអោយមីងទិញអាណាកាលីប
កាលីប អោយមីងហាំ បើថាទិញអាវមនុស្សចាស់អោយមីងមីអត់ពាក់ទេ!!

ក៖ ហ៊ឺ!!!
អ្នកមីងមួយនេះគឺជាសំនួរមួយចុងក្រោយអ្នកមីងមានពាក្យពេចន៍អីចង់ផ្ដែផ្ដាំទៅកាន់កូនចៅអ្ន
កមីងជំនាន់ក្រោយអោយពួកគាត់ដើរលើផ្លូវអីដែរអ៊ីចឹងណាស់!!

ខ៖ ញ៉ុមចេះតែចង់អោយកូនញ៉ុមដើរលើផ្លូវល្អ មិនចង់អោយកូនដើរលើផ្លូវដែរអាក្រក់ទេ!!

ក៖ ចាំ!!

ខ៖ ញ៉ុមនិយាយជាមួយកូនញ៉ុមអាពៅញ៉ុមវាចេះដើរតាម មិនសូវនេះទេ
ដើរទៅណាញ៉ុមដើរតាមហើយ!!

ក៖ ចាំ!!

ខ៖ ញ៉ុមធ្វើការអីក៏ដោយ ធ្វើការដូចថាអាហ្នឹង ធ្វើការមួយខែគេកាត់ថ្មីម្ដងហា!!

ក៖ ចាំ!!

ខ៖ បើញ៉ុមអត់ធ្វើអីញ៉ុមដើរតាមវាហើយ!!

ក៖ ចាំ!!

ខ៖ ដើរតាមកូនពៅ!!

ក៖ ចាំ!!

ខ៖ ចេះតែដើរតាម។

ក៖ អ្នកមីងកូនទាំងអស់សុទ្ធតែអោយរៀនទាំងអស់គ្នាតើមីងហោ?

ខ៖ អោយរៀន តែអានេះវារៀនអត់ចេះ!!

ក៖ ឥឡូវឈប់រៀនហើយ?

ខ៖ ឈប់រៀនហើយ!!

(កូន)៖អាចូលរៀនលែងចង់ចូលហើយ។

ក៖ ម៉េចអញ្ចឹង?

ខ៖ ចូលវាអញ្ចេកនិយាយថាចូលទៅថ្នាក់ក្រោមថ្នាក់ទី៧ហើយវាប៉ុណ្ណាណីហើយ!!

ក៖ អើយមកពីយើងត្រឡោកទេ កុំគិតដោយសារកំពស់ហ្នំ!!

ខ៖ អោយទៅរៀនវាអត់ព្រម!!

ក៖ ហោងហើយបានខ្ពស់ហ្នំ!!

(មិត្តភក្តិ)៖ហើយឈប់រៀនបានប៉ុន្មានខែហើយ?

(កូន)៖ ២ ៣ខែហើយ។

ក៖ អូយចូលរៀនវិញទៅដើម្បីអនាគតហាំ!! ហ្នឹងពេលហ្នឹងមីងហាអត់ទាន់ស្តាយទេណាស់ មីងឯងចាំមើលទៅពេលគាត់អាយុច្រើនទៅគាត់និងស្តាយក្រោយពីពេញម៉ាជីវិតគាត់ម៉ង!!

ខ៖ អើយនេះកូនញ៉ុមអាមួយចូលយេស៊ូវ ថាហ្អែងឥលូវហ្អែងនៅទូចហ្អែងអត់ទាន់ដឹងទេ!!

ក៖ ចាំ!!

ខ៖ ចាំមើលតិតទៀតទៅ!!

ក៖  ចូលរៀនវិញទៅ អត់ទាន់ហួសពេលទេ មុខក្មេងណាស់លោកម្ចាស់ ហើយទៅឈប់រៀនធ្វើស្អីគេ ហើយអាយុប៉ុន្មាន ប៉ុន្មានដប់ឆ្នាំ?

(កូន)៖ ១៥ ១៦។

ក៖  ១៥ ១៦ហ្នឹង!!ហើយអើយឈប់រៀនថ្នាក់ទីប៉ុន្មាន ទី៧ ឬក៏ទី៨?

(កូន)៖ទី៧។

ក៖  ហ្នឹងហើយ ប៉ុណ្ណឹងមានអី គេត្រូវតាមស្តង់ដារគេហើយ។

ក៖ ឪវាស្លាប់ហ្នឹងហិ ទៅសុំជីដូនមួយជីទូតមួយនេះហិ គេថាអោយទៅរៀនវិញទៅ!!

ក៖ ចាំ!!

ខ៖  ដល់ពេលសុំហើយអីហើយវាថាវាអត់ទៅរៀន!!

ក៖ អើយអូនល្ងើយកុំគិតអញ្ចឹងទៅវិញទៅដើម្បីអនាគត!!

ខ៖  វាអត់រៀន!!

ក៖  បើសិនជាគិតពីអនាគតខ្លួនឯងស្រលាញ់ក្រុមគ្រួសារ ចង់មានប្រពន្ធអ្នកមានអីអញ្ចឹងណាស់ គឺថាទៅរៀនទៅមីង គឺថាមិនបានរៀនពូកែដូចគេអោយបានប្រឡងគេប្រឡងឯងទៅយូរៗទៅក៏វាជ្រៀតចូលនៅក្នុងគំណិតបានខ្លះៗដែរ។

ខ៖  ញ៉ុមថាញ៉ុមអោយវាទៅរៀនទៅ!!

ក៖  ចាំហ្នឹងហើយ!!ចាំអញ្ចឹងអ្នកមីងមានអីចង់ផ្តែផ្តាំទៅកាន់កូនចៅអីទៀតអត់?

ខ៖  ចង់និយាយថាចង់ថានេះញ៉ុមចង់ណែនាំកូនអោយដើរផ្លូវល្អកុំអោយដើរផ្លូវអាក្រក់។

ក៖ ហ្នឹងហើយ ចូលរៀនចូលអីទៅអូនអើយ!!!

ខ៖  ឃើញអាខ្លះហ្នឹងចេះតែដើរ ញ៉ុមមិនចង់អោយវាដើរលេងអីទៅ ខ្លះទៅគេជក់ម៉ា!!

ក៖  ហ្នឹងហើយ!!

ខ៖  គេអោយវាថា ហ្អែងសាកមើលមើល!!

ក៖ ហ្នឹងហើយ!!

ខ៖  ហ្នឹងញ៉ុមខ្លាចអញ្ចឹងហាំ ថានិយាយទៅកូនញ៉ុមហ្នឹងញ៉ុមដើរតាម។

ក៖ ចាំ!!

ខ៖  ទៅណាញ៉ុមទៅហ្នឹង!!

ក៖ ចាំ!!

ខ៖  ហ្នឹង!!

ក៖ ទៅទៅ ទៅរៀនទៅទៅរៀនអង់គ្លេសទៅរៀនអីទៅ ដើម្បីអនាគត!!

(មិត្តភក្តិ)៖ គេអោយសាកកុំណាស់!!

(កូន)៖ ញ៉ុមអត់ទេ!!

ក៖  កុំអោយសោះ
អាហ្នឹងមានតែគេចាប់បានមានតែគុកមួយទេ!!អាអ្នកជក់អាអ្នកលក់គឺថាត្រូវតែគុកទាំងអស់
គ្រាន់តែអាមួយតិចឆ្នាំអាមួយនេះច្រើន!!

ខ៖  ហ្នឹតងហើយ!!

ក៖ មីងជាប់គុកណាស់មិនមែនស្រួលទេណាស់!!

ខ៖  មិនមែនស្រួលទេ!!

ក៖  ទៅណាអត់បានទេ!

ខ៖  អាហ្នឹងគុកហ្នឹងវ៉េ!!

ក៖ ហ្នឹងហើយ!!

ខ៖ វាវ៉ែទៀត!!

ក៖  ហ្នឹងហើយ!!ប៉ុន្តែអាអ្នកក៏ត្រូវតែជាប់ដែរ
អ្នកណាជក់គ្រឿងញៀនគឺប្រព្រឹត្តអំពើរំលងនឹងច្បាប់!!ជាប់គុក គឺត្រូវតែជាប់ហើយ!!

ខ៖  ហ្នឹងត្រូវតែជាប់ហើយ!!

ក៖  ហ្នឹងហើយ ស្តមរកសាច់រកឈាមគ្មាន
ទីបញ្ចប់គឺថាអ្នកណាខ្លះបែកថ្នាំអីវ៉ាន់សម្លាប់ខ្លួនអីវ៉ាន់ណោះមីងណាស់!!

ខ៖  ហ្នឹងហើយៗ!!

ក៖  ឬក៏ទៅធ្វើជាចោរទៅធ្វើជាអីទៅណាណីផ្សេងអីអញ្ចឹងទៅណាស់!!

(កូន)៖ ដូចបរទេសអីវ៉ាន់មកនៅខ្មែរ ជក់អីវ៉ាន់អស់លុយអីហើយមកដេកនៅនឹងផ្លូវ!!

ក៖  ហ្នឹងហើយ!!

ខ៖  ជក់អីចឹងមកសំលុតម៉ែយកលុយហាំ!!

ក៖ ចាំ!!

ខ៖  វាហ៊ានសម្លាប់ម៉ែហាំ!!

ក៖ ចាំហ្នឹងហើយ!

ខ៖  ជក់អាហ្នឹងហាំ!!

ក៖  អីចឹងមីងបង្ហំអោយទៅវិញ ទោះតែមិននេះអីវ៉ាន់ចេះតែជំរុញទៅមីងណាស់!!

ខ៖  វាជំរុញទៅតែវាអត់ទៅ!!

ក៖  អាអូនអើយត្រលប់ទៅសាលាវិញទៅកុំយកអនាគតខ្លួនឯងមកបោះចោលទទេ!!

(មិត្តភក្តិ)៖ ហ្នឹងអូនឯងអាយុតិចទៀតដឹងខ្លួនហើយ។

កៈ ហ្នឹងហើយទឹមតែឈប់២ខែអឺចឹងអត់ទាន់ហួសពេលទេ!!សុំគ្រូចូលវិញទៅ សម័យឥឡូវអាចសុំចូលវិញបានទេ។សាលាជិតតែមួយសោះហ្នឹង!!

(មិត្តភក្តិ)៖ ទៅទៅរៀនវិញហ្ហ៎!!

ខៈ ទៅ ទៅញ៉ុមសុំគេ២ដងហើយ សុំមុនឪវាអត់ទាន់ឈឺអត់ទាន់ស្លាប់ហ្ហ៎!!គេថាចូលរៀនវិញទៅអ៊ុំទុកហើយ!!

កៈ ហ៊ឺ!!

ខៈ ដល់ពេលឪវាស្លាប់ហ្នឹងញ៉ុមទៅសុំគេ ញ៉ុមថាអូនល្ងើយកាលប៉ាវាស្លាប់ហ្នឹងវាអត់បានចូលរៀនឥឡូវញ៉ុមសុំអោយវាចូល អោយវាចូលរៀនថ្នាក់ទី៧ ខំទិញសៀវភៅខំទិញអីអោយវាវាអត់រៀន!!

កៈ ហ៊ឺតាមហ្នឹងទៅមីង ខំប្រឹងជំរុញអោយទៅរៀន មីងនិយាយទៅអនាគត!!

ខៈ ញ៉ុមនឹកឃើញថាវានៅទូចៗគេរៀនហា៎ហើយវាទៅវាធំជាងគេដល់អញ្ចឹងទៅ !!

កៈ ដោយសារគាត់ត្រឡោកគាត់ខ្ពស់ អញ្ចឹងកុំខ្វល់!!

ខៈ ញ៉ុមណែនាំម៉េចក៏ដោយវាអត់!!

(មិត្តភក្តិ)៖ តែអក្សរអីវាមើលរួចអស់ហើយហី?

កៈ ចា៎ ទី៧ហើយ!!ចា៎អញ្ចឹងអរគុណច្រើនអ្នកមីងហា៎សំរាប់ការសំភាសន៍នៅក្នុងថ្ងៃនេះហើយអ្វីទាំងអស់កូនចៅអ្នកមីអគាត់នឹងបានស្តាប់ពីប្រវត្តិអ្នកមីងទៅថ្ងៃខាងក្រោយ ចា៎អរគុណច្រើនអ្នកមីង។